# សង្ខេបការរកឃើញ និងអនុសាសន៍
# សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
# និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោត
# ឆ្នាំ២០១៨

**១. ការរៀបចំការចុះឈ្មោះបោះឆ្នោត៖** ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត បានធ្វើឡើងជារៀងរាល់ឆ្នាំ។ ការចុះឈ្មោះឆ្នាំ២០១៨នេះ មានរយៈពេល ១៨ថ្ងៃ ជាមួយប្រជាពលរដ្ឋប៉ាន់ប្រមាណនៃអ្នកគ្រប់អាយុបោះឆ្នោតចំនួន ៩,៩០៨,២៤៣នាក់ និងការិយាល័យបោះឆ្នោតប៉ាន់ប្រមាណចំនួន ២៣,៤៧០ ការិយាល័យ។ ដំណើរការចុះឈ្មោះបោះឆ្នោត មានក្រុមចុះឈ្មោះបោះឆ្នោត ចំនួន ១៦៤៦ក្រុម ដែលមានមន្ត្រីជាប់កិច្ចសន្យាបំរើការងាររយៈពេលខ្លី ចំនួន ៣,២៩២នាក់។

**២. ការបង្កើតការិយាល័យបោះឆ្នោត និងស្ថិតិប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត៖** ការិយាល័យបោះឆ្នោតត្រូវបានបង្កើតឡើងបន្ថែមជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ២០១៨ គ.ជ.ប បានបង្កើតការិយាល័យបន្ថែម ៣២៧ លើការិយាល័យដែលមានស្រាប់ក្នុងឆ្នាំ២០១៧។ ក្នុងចំណោមអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៨ គ.ជ.ប បានប៉ាន់ប្រមាណអ្នកចុះឈ្មោះថ្មីសម្រាប់ឆ្នាំ២០១៨ ចំនួនប្រមាណ ៤៨៩,៩៦៣នាក់។ ថ្ងៃដែលមានប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតច្រើនជាងគេ ខុមហ្វ្រែល សង្កេតឃើញកើតមានក្នុងអំឡុងពេល មុន និងក្រោយ ២ថ្ងៃនៃថ្ងៃបុណ្យភ្ជុំបិណ្ឌ (ថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែតុលា ជាថ្ងៃបុណ្យ)។ ស្ថិតិនៃការចុះឈ្មោះតាមគ្រប់រាជធានីខេត្ត មានចំនួនប្រហាក់ប្រហែលគ្នា មិនដូចជាការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ ដែលខេត្តមួយចំនួន មានចំនួនអ្នកចុះឈ្មោះលើសពី ១០០ភាគរយ នៃតួលេខប៉ាន់ប្រមាណ។

**៣. បរិយាកាសទូទៅទាក់ទងការចុះឈ្មោះបោះឆ្នោត៖** ការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅតាមផែនការគ្រោងទុកនៃ បទបញ្ជា និងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត។ ខុមហ្វ្រែល បានសង្កេតឃើញថា គ.ជ.ប បានចេញសេចក្តីប្រកាសព័ត៌មានពីការចុះឈ្មោះបោះឆ្នោតនៅតាមឃុំសង្កាត់ និងណែនាំឱ្យមានការចុះឈ្មោះដល់ភូមិក្នុងគោលបំណងផ្តល់សេវាឱ្យកាន់តែជិតលំនៅឋានប្រជាពលរដ្ឋ។ បន្ថែមពីសេចក្តីប្រកាសរបស់ គ.ជ.ប ខុមហ្វ្រែលបានសង្កេតឃើញថា ក្រុមចុះឈ្មោះបោះឆ្នោត បានបែងចែកថ្ងៃសម្រាប់ចុះឈ្មោះបោះឆ្នោតតាមភូមិ មានចំនួនថ្ងៃច្រើនជាងចុះនៅសាលាឃុំសង្កាត់។

ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត មានគណបក្សនយោបាយចំនួន ៣ដែលបានចូលរួមសង្កេតមើលដំណើរការចុះឈ្មោះគឺ គណបក្សប្រជាជនកម្ពុជា គណបក្សយុវជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច។ សម្រាប់អង្គការសង្គមស៊ីវិលនៃអតីតៈបន្ទប់ស្ថានការណ៍ ខុមហ្វ្រែល មិនបានសង្កេតឃើញមានអង្គការណាមួយ ចូលរួមនោះទេ លើកលែងតែ ខុមហ្វ្រែលខ្លួនឯង។

ទាក់ទងការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋពីការចុះឈ្មោះបោះឆ្នោត សកម្មភាពចូលរួមរបស់សង្គមស៊ីវិល ខុមហ្វ្រែល សង្កេតឃើញថាមិនសូវមានភាពផុលផុស ដូចកាលឆ្នាំ២០១៦ នោះទេ។ ប៉ុន្តែ ស្ថានប័ន គ.ជ.ប បានបង្កើនការផ្សព្វផ្សាយនូវកម្មវិធីរបស់ខ្លួន តាមទូរទស្សន៍របស់រដ្ឋ និងឯកជនសកម្មជាងមុន។

**៤. ការសង្កេតដំណើរការចុះឈ្មោះបោះឆ្នោត៖** ការសង្កេតនៅក្នុងទីតាំងដែលបានកំណត់ទុកនោះ ភាគច្រើននៃទីតាំងចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍បានសង្កេតឃើញថា ក្រុមចុះឈ្មោះបានយកចិត្តទុកដាក់រៀបចំកាលវិភាគ និងប្រកាសជាព័ត៌មានច្បាស់លាស់ដល់អ្នកចុះឈ្មោះបោះឆ្នោតក្នុងមូលដ្ឋាន ពីពេលវេលា និងទីតាំងនៃការចុះ

ឈ្មោះ។ ការរៀបចំទីតាំងចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលសង្កេតឃើញថា ភាគច្រើននៃទីតាំងមានលក្ខណៈងាយស្រួល និងសមស្របដល់គ្រប់អ្នកចុះឈ្មោះបោះឆ្នោត។ ការិយាល័យចុះឈ្មោះបោះឆ្នោត ភាគច្រើន បើកដំណើរការជារៀងរាល់ថ្ងៃតាមពេលវេលាកំណត់។ ក្រុមចុះឈ្មោះបោះឆ្នោត ភាគច្រើនមានវត្តមានគ្រប់ចំនួន ក្នុងទីតាំងចុះឈ្មោះបោះឆ្នោត ហើយបានបំពេញតួនាទី និងភារកិច្ចយ៉ាងត្រឹមត្រូវ។ ប៉ុន្តែទោះជាយ៉ាងណា អ្នកសង្កេតការណ៍សង្កេតឃើញថា ពលរដ្ឋមានសិទ្ធិមកសុំចុះឈ្មោះបោះឆ្នោតមិនមានចំនួនច្រើន ដូចកាលចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១៦ នោះទេ។

**៥. ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៨៖** ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៨ ខុមហ្វ្រែលបានរកឃើញថា ក្នុងចំណោមឈ្មោះអ្នកបោះឆ្នោតមានក្នុងបញ្ជីចំនួន ៨,៥៤៤,៨៨៥ឈ្មោះ មានឈ្មោះ ៨៩ឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ដែលមានទិន្នន័យដូចគ្នា។ ឈ្មោះដូចគ្នានេះ (ស្ទួន) បើប្រៀបធៀបជាមួយឆ្នាំ២០១៧ ឃើញថាមានតួលេខថយចុះ (ចំនួនឈ្មោះស្ទួនមានចំនួន ៩៦១ឈ្មោះ កាលឆ្នាំ២០១៧)។

ការប្រើប្រាស់ឯកសារសម្រាប់ចុះឈ្មោះបោះឆ្នោតក្នុងចំណោម ៨,៥លានឈ្មោះ មាន ២៦,៧៣៩ឈ្មោះ ដែលមានលេខសំគាល់ ឯ.អ ឬ អ.ខ ដូចគ្នា។ ម្យ៉ាងទៀតការប្រើប្រាស់ឯកសារនេះ ប្រជាពលរដ្ឋអ្នកមានសិទ្ធិបោះឆ្នោត បានប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ រហូត ៩៥ភាគរយ (អ.ខទាំង ៣ប្រភេទ)។

សុពលភាពនៃបញ្ជីឈ្មោះបោះឆ្នោត បន្ទាប់ពីការផ្ទៀងផ្ទាត់ ខុមហ្វ្រែល បានរកឃើញថា ប្រជាពលរដ្ឋ ៩១ ភាគរយ នៃប្រជាពលរដ្ឋដែលមានវត្តមាននៅក្នុងប្រទេស មានឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៨ និងគុណភាពនៃបញ្ជីឈ្មោះបោះឆ្នោតដែលចាត់ទុកថាព័ត៌មានដូចគ្នា (ឈ្មោះ ភេទ ឆ្នាំកំណើត) មានរហូតដល់ ៩៥.៦ ភាគរយ ក្រៅពីនោះមានចំណុចខុសគ្នាខ្លះៗ តែវាមិនអាចនាំឱ្យមានការបាត់បង់សិទ្ធិនោះទេ បើសិនជាស្ថាប័ន គ.ជ.ប មានសេចក្តីណែនាំពីការប្រើប្រាស់ឯកសារពេលបោះឆ្នោត។ គុណភាពនៃបញ្ជីឈ្មោះនេះ បើប្រៀបធៀបជាមួយការរកឃើញឆ្នាំ២០១៦ និងឆ្នាំ២០១៧ ឃើញថាមានភាពប្រសើរឡើង។ ខុមហ្វ្រែល មិនមានលទ្ធភាពសិក្សាពីប្រជាពលរដ្ឋដែលរស់នៅខាងក្រៅប្រទេសជាង ២លាននាក់នោះទេ។ ទោះជាយ៉ាងណា ចំនួនភាគច្រើននៃអ្នករស់នៅខាងក្រៅប្រទេសនេះ ពួកគេមិនមានលទ្ធភាពត្រឡប់មកចូលរួមចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលចុះឈ្មោះនោះ ផងដែរ។

## អនុសាស្រ្តសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

បទបញ្ញា និងនីតិវិធី ត្រូវបានធ្វើការកែសម្រួលសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ក្នុងនោះមាន៧ជំពូក និង៥៥ប្រការ។ ជំពូកនិមួយៗ មានការកែប្រែចំណុចមួយចំនួន ក្នុងនោះជំពូកដែលមានការកែតម្រូវ និងបន្ថែមច្រើនជាងគេគឺជំពូកទី៦ និងជំពូកទី៧។ ជំពូកទី៦ និយាយអំពីដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលមានគោលគំនិតសំខាន់ៗ ដូចខាងក្រោម៖

- ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត រួមមានការលុបឈ្មោះអ្នកដែលទទួលមរណភាព អ្នកដែលបានដកហូតសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន និងអ្នកដែលបានផ្លាស់ប្តូរលំនៅឋាន ឬទីសំណាក់ទៅឃុំសង្កាត់ផ្សេង ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យអ្នកបោះឆ្នោត។
- ការចុះឈ្មោះបោះឆ្នោត ក្នុងជំហានទី៤ ដែលអនុវត្តដោយកុំព្យូទ័រ បានបន្ថែមប្រវត្តិចុះឈ្មោះបោះឆ្នោតបន្ទាប់ពីថត អ.ខ ឬឯ.អ។
- ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត តាមករណីផ្សេងៗ របស់អ្នកចុះឈ្មោះបោះឆ្នោតម្នាក់ៗ ដូចជា ករណីគ្មាន អ.ខ អ្នកចុះឈ្មោះខុសទិន្នន័យ...។

– ការរៀបចំបញ្ជីឈ្មោះបោះឆ្នោតដំបូង ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យដោយការីកុំព្យូទ័រនៃនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត។

ក្នុងឆ្នាំ២០១៨ ក៏ដូចជាឆ្នាំកន្លងមកផងដែរ ខុមហ្វ្រែលបានចូលរួមផ្តល់នូវមតិយោបល់ទៅលើការកែសម្រួលបទបញ្ញា និងនីតិវិធីប្រចាំឆ្នាំរបស់ខ្លួន ដើម្បីឱ្យមានភាពល្អប្រសើរ។ អនុសាសន៍ទាក់ទងបទបញ្ញា និងនីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានផ្ញើជូន គ.ជ.ប តាមជំពូកនិមួយៗ នូវអ្វីដែលខុមហ្វ្រែលយល់ឃើញថា ត្រូវការកែសម្រួល។ ខាងក្រោមនេះជាអនុសាសន៍ សម្រាប់ស្ថានប័ន គ.ជ.ប ក្នុងការពង្រឹងបន្ថែមក្នុងដំណើរការចុះឈ្មោះ។

**ក. អនុសាសន៍ទូទៅ**

- ស្វែងរកយន្តការជម្រុញឱ្យមានច្បាប់ ឬនីតិវិធីចុះឈ្មោះប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលបានចំណាកស្រុកទៅក្រៅប្រទេស
- ជំរុញដល់ក្រុមការងារចុះឈ្មោះបោះឆ្នោតឱ្យយកចិត្តទុកដាក់ក្នុងការចុះឈ្មោះបោះឆ្នោត ដើម្បីកុំឱ្យមានឈ្មោះស្ទួន ឬមានកំហុសបច្ចេកទេសក្នុងការបញ្ចូលព័ត៌មាន
- លើកទឹកចិត្តដល់ភាគីពាក់ព័ន្ធក្នុងការចូលរួមអប់រំប្រជាពលរដ្ឋ ដោយមិនត្រូវមានការរារាំងពីអាជ្ញាធរ
- ក្រៅពីការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ គួរតែបង្កើនការទទួលខុសត្រូវ(អាចមានកញ្ចប់ថវិកា)ដល់មេភូមិ អនុភូមិ សម្រាប់ផ្តល់ព័ត៌មានទាក់ទងការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋគ្រប់និន្នាការនយោបាយ
- បង្កើនពេលវេលាចុះឈ្មោះតាមភូមិឱ្យបានច្រើនជាងពេលវេលាចុះឈ្មោះនៅសាលាឃុំសង្កាត់
- គ.ជ.ប គួរតែទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ និងជជែកពីលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(អ.ខ)ដែលជាប្រភេទទី៣ ដូចគ្នា ដែលអ្នកបោះឆ្នោតបានប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងដើម្បីជួយធានាថាអ្នកបោះឆ្នោតម្នាក់មានទិន្នន័យតែមួយ
- គ.ជ.ប ខិតខំកែសម្រួលលេខអត្តសញ្ញាណបញ្ជាក់ការចុះឈ្មោះបោះឆ្នោត(ឯ.អ) ដើម្បីកុំឱ្យមានលេខជាន់គ្នា និងឱ្យក្លាយជាលេខតែមួយចំពោះលេខណាដែលដូចគ្នា

**ខ. អនុសាសន៍ទាក់ទងបទបញ្ញា និងនីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត**

ខុមហ្វ្រែល បានផ្ញើអនុសាសន៍ទៅស្ថាប័ន គ.ជ.ប នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ នូវអ្វីដែលបានរកឃើញ។ យោងតាមការសិក្សារបស់ខុមហ្វ្រែល ជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន អ្នកជំនាញការបោះឆ្នោត អនុសាសន៍សម្រាប់ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ផ្តល់ជូនដូចខាងក្រោមៈ

ខ.១ សម្រាប់កែលម្អសេចក្តីព្រាងបទបញ្ញា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៨

1. នីតិវិធី និងក្រុមចុះឈ្មោះបោះឆ្នោតសម្រាប់ពលករចំណាកស្រុកនៅក្រៅប្រទេសៈ ពិនិត្យលទ្ធភាពក្នុងការរៀបចំ នីតិវិធីលើនីតិវិធីដែលមានស្រាប់ និងបង្កើតក្រុមចុះឈ្មោះបោះឆ្នោត ដែលអាចឱ្យពលករចំណាកស្រុកនៅប្រទេសថៃ មានលទ្ធភាពអាចចុះឈ្មោះបោះឆ្នោត តាមបន្ទាត់ព្រំដែន នៃព្រះរាជាណា

ចក្រកម្ពុជា។ គ.ជ.ប គួរចេញជាសេចក្តីណែនាំដោយឡែកទៅអាជ្ញាធរអំពីការចេញលិខិតបញ្ជាក់ទីសំណាក់ (ទីលំនៅមិនច្បាស់លាស់) សំរាប់ឲ្យពលករចំណាកស្រុកនៅប្រទេសថៃប្រើប្រាស់ក្នុងការ ចុះឈ្មោះបោះឆ្នោត។ រាជរដ្ឋាភិបាលកម្ពុជា គួរធ្វើសំណើជាផ្លូវការទៅរាជរដ្ឋាភិបាលថៃសុំអនុញ្ញាតឱ្យពលករមានថ្ងៃឈប់សម្រាក និងលើកលែងការបង់ថ្លៃទិដ្ឋាការសម្រាប់ការចេញចូលចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ចំពោះពលករចំណាកស្រុកនៅប្រទេសថៃ ដែលមិនទាន់បានចុះឈ្មោះ បោះឆ្នោតនៅឆ្នាំ២០១៧។

2. **ភ្នាក់ងារគណបក្សនយោបាយ (ជំពូកទី៥)៖** ការហាមឃាត់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ស្រុកខណ្ឌ ក្រុង ឃុំសង្កាត់ មេភូមិ ជំនួយការមេភូមិ និងកងកំលាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយ ក្នុងប្រការ ៥.១.៥ គ.ជ.ប ត្រូវបន្ថែមពាក្យ«ប្រជាការពារភូមិ»មួយទៀត ពីព្រោះពួកគាត់ត្រូវបានជ្រើសរើសដោយមេភូមិ ឬមេឃុំ។
3. ការផ្ទៀងផ្ទាត់ស្ថិតិអ្នកចុះឈ្មោះប្រចាំថ្ងៃ**(ប្រការ៦.១១)៖** នាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបញ្ជីឈ្មោះបោះឆ្នោត ត្រូវតែលុបទិន្នន័យចាស់លើកុំព្យូទ័រឱ្យអស់ ដើម្បីកុំឱ្យនៅសល់ពេលក្រុមចុះឈ្មោះយកកុំព្យូទ័រទៅប្រើប្រាស់ នាំឱ្យបង្កើតជាឈ្មោះស្ទួន។ គ.ជ.ប ត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យទាំងចាស់និងថ្មីឱ្យបានចប់សព្វគ្រប់មុនចេញបញ្ជីដំបូង (ឬបន្ថែមពេលវេលា ករណីមិនគ្រប់គ្រាន់) ដើម្បីកំណត់និងធានាថា អ្នកបោះឆ្នោត ១នាក់ មានឈ្មោះតែមួយនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។
4. ទិន្នន័យបញ្ជីឈ្មោះបោះឆ្នោតសម្រាប់ការធ្វើសវនកម្ម ឬការផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោត**(ជំពូកទី៦)**៖ គ.ជ.ប គួរផ្តល់ទិន្នន័យបញ្ជីឈ្មោះបោះឆ្នោត (PDF ទន់ ដែលមិនមែនជា PDF រឹង ជារូបភាព) ដែលអាចបំលែងជាទិន្នន័យវិភាគបាន(អត្តលេខ នាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែង និងការិយាល័យ) ដោយកុំព្យូទ័រដល់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលសម្រាប់ធ្វើសវនកម្ម ដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅ គ.ជ.បវិញអំពីគុណភាពនៃបញ្ជីបោះឆ្នោត។ (ប្រការ ៦.១១.១១ និង៦.១៣.៤)។

5. ការទទួល ការអង្កេត និងការដោះស្រាយបណ្តឹងទាក់ទិនការចុះឈ្មោះបោះឆ្នោតៈ (ជំពូកទី៧)
   - លើកកម្ពស់ប្រជាពលរដ្ឋឱ្យដោយផ្ទាល់ក្នុងនីតិវិធីបណ្តឹង៖ តាមរយៈការស្នើសុំរបស់អ្នកប្តឹង និងក្នុងករណីអ្នកប្តឹងមិនអាចមានសមត្ថភាពសសេរពាក្យបណ្តឹងបាន ក្រុមប្រឹក្សា ឃុំ/សង្កាត់ ឬ គ.ជ.ប ជួយសរសេរពាក្យបណ្តឹងឲ្យ ដើម្បីឱ្យអ្នកប្តឹងប្រើប្រាស់យន្តការប្តឹង ដោយខ្លួនឯងជាជាងប្រើប្រាស់យន្តការប្តឹងដោយអ្នកតំណាង។ (ប្រការ ៧.២.១ និងប្រការ ៧.២.៩ នៃផ្នែកទី១ អំពី៖ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹង ការចុះឈ្មោះបោះឆ្នោត និង ប្រការ ៧.៣.៣ ប្រការ ៧.៣.១២ នៃផ្នែកទី២អំពី៖ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីឈ្មោះបោះឆ្នោតដំបូងនៃជំពូកទី៧)។ បណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោតដំបូង គឺជាយន្តការចាំបាច់ក្នុងការផ្ទៀងផ្ទាត់ការ ផ្តល់ និងដកហូតសិទ្ធិចុះឈ្មោះបោះ ឆ្នោតដែលជាមូលដ្ឋាននៃសិទ្ធិនយោបាយ។ ស្ថាប័នរៀបចំការបោះឆ្នោតថ្នាក់ជាតិ និងមូលដ្ឋានត្រូវធានាឲ្យបាននូវយន្តការមួយ ដើម្បីឲ្យប្រជាពលរដ្ឋចូលរួមអនុវត្តសិទ្ធិនេះឲ្យបានពេញលេញ ដោយខ្លួនឯងផ្ទាល់។ ការតម្រូវឲ្យប្រជាពលរដ្ឋសសេរពាក្យបណ្តឹងដោយខ្លួនឯង ឬតាមរយៈអ្នកតំណាងនៅតែជា

បញ្ហារារាំងដល់ការចូលរួមប្រើប្រាស់យន្តការបណ្តឹងនេះ ក្នុងការ អនុវត្តសិទ្ធិនយោបាយរបស់ខ្លួន ដោយសារប្រជាពលរដ្ឋភាគច្រើននៅតំបន់ជនបទ មិនមានសមត្ថភាពក្នុងការសរសេរពាក្យបណ្តឹងដោយខ្លួនឯង ឬប្រើប្រាស់យន្តការអ្នកតំណាងឡើយ។ ម្យ៉ាងទៀត គណបក្សនយោបាយត្រូវបានគេឃើញថាភាគច្រើន បានដើរតួនាទីជាអ្នកតំណាងក្នុង បណ្តឹងនេះដែលជាហេតុនាំឲ្យមានការរើសអើងផ្នែកនយោបាយពាក់ព័ន្ធនឹងការអនុវត្តន៍ សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ។

- កែលម្អប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹង៖ បង្កើតយន្តការទទួល និងអង្កេតពាក្យបណ្តឹងនៅ គ.ជ.ប លធ/ខប និងក្រុមប្រឹក្សា ឃុំ សង្កាត់។ យន្តការនេះបង្កើតឡើងដើម្បីស៊ើបអង្កេតគ្រប់បណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ជាពិសេសបណ្តឹងទាក់ទងបទល្មើស ដែលបំពានបទប្បញ្ញត្តិជំពូកទី១០ នៃច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ក្នុងការដោះស្រាយបណ្តឹង វាមានភាពចាំបាច់ក្នុងការស្រាវជ្រាវ ផ្ទៀងផ្ទាត់ និងប្រមូលភស្តុតាងសម្រាប់បណ្តឹងជំទាស់ ជាពិសេសបទល្មើសដាក់ពិន័យ និងដកសិទ្ធិបោះឆ្នោត។
- ឯករាជ្យភាពរបស់គណៈកម្មការប្រជុំផ្សះផ្សា/ប្រជុំសម្រេច៖ បង្កើតយន្តការតាមនីតិវិធីច្បាប់មួយ ដើម្បីធានាឲ្យបាននូវឯករាជ្យភាពរបស់គណៈកម្មការប្រជុំផ្សះផ្សា/ប្រជុំសម្រេច។ ក្នុងការអនុវត្តន៍នាពេលបច្ចុប្បន្ន ក្រុមប្រឹក្សាឃុំ សង្កាត់គឺជាសមាជិកនៃគណៈកម្មការប្រជុំផ្សះផ្សាប្រជុំសម្រេចនៃបណ្តឹងបោះឆ្នោត។ ក្រុមប្រឹក្សាឃុំ/សង្កាត់ គឺជាមន្រ្តីជាប់ឆ្នោតមកពីគណបក្សនយោបាយដែលអាចជាភាគីមានទំនាស់ផលប្រយោជន៍នយោបាយ ក្នុងដំណើរការដោះស្រាយបណ្តឹង។ យោងតាមគោលការណ៍ច្បាប់ ក្រុមប្រឹក្សាឃុំ/សង្កាត់មិនទាន់ទទួលបានការជឿទុកចិត្ត និងមានឯករាជ្យពេញលេញនោះទេ។
- លើកកម្ពស់តម្លាភាព និងការចូលរួមក្នុងសវនាការ៖ គ្រប់សវនាការរបស់ គ.ជ.ប ដូចជាសវនាការសង្ខេប សវនាការប្រតិបក្ស និងសវនាការសួរដេញដោលត្រូវធ្វើជាសាធារណៈ និងផ្តល់ភាពងាយស្រួលដូចជា ទីកន្លែង និងពេលវេលា ដល់ការចូលរួមរបស់ភាគីពាក់ព័ន្ធ។

### ខ.២ យន្តការដើម្បីគាំទ្រ ពង្រឹងភារកិច្ច និងសមត្ថកិច្ចរបស់ គ.ជ.ប ជាមួយអាជ្ញាធរ និងភាគីពាក់ព័ន្ធ

1. ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោតៈ ស្នើសុំដល់ក្រសួងមហាផ្ទៃបន្តចេញអត្ត សញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងសំបុត្រកំណើត ឱ្យអ្នកមានសិទ្ធិបោះឆ្នោតឱ្យបានគ្រប់គ្នា១០០%។ គ.ជ.ប បន្ថែមឱ្យបានច្បាស់ពី អ.ខ អស់សុពលភាព ក្នុងចំណុច ៦.៤.៦.១ អាចឱ្យចុះឈ្មោះបាន ដូចកាលចុះឈ្មោះឆ្នាំ២០១៧ កន្លងមក។
2. ការអប់រំ ផ្សព្វផ្សាយអំពីការបោះឆ្នោតៈ គ.ជ.ប ត្រូវចេញសេចក្តីណែនាំទៅអាជ្ញាធរមានសមត្ថកិច្ច (អាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់) ដើម្បីផ្តល់ការគាំទ្រ សម្រួល និងសហការជាមួយភាគីពាក់ព័ន្ធ ដែលរួមមាន គណបក្សនយោបាយ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអង្គការ មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែល គ.ជ.ប ទទួលស្គាល់ ធ្វើសកម្មភាពអប់រំ និងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត។ ជាពិសេសបង្កើនការផ្សព្វផ្សាយតាមរយៈប្រព័ន្ធទូរគមនាគមន៍គ្រប់ប្រព័ន្ធ ដូចដែល គ.ជ.ប បានអនុវត្តក្នុងដំណាក់កាលមុនការបោះឆ្នោតឆ្នាំ២០១៨។
3. យន្តការថ្នាក់ជាតិសម្រាប់ការបោះឆ្នោតៈ បង្កើតយន្តការរួមថ្នាក់ជាតិ (ច្រកតែមួយ) ដើម្បីចែករំលែកព័ត៌មាន ជួយអន្តរាគមន៍ និងសម្របសម្រួលកែតម្រូវករណីភាពមិនប្រក្រតី ការអនុវត្តន៍ខុសក្រមសីល

ធម៌ ការមិនយល់សមត្ថកិច្ច/ភារកិច្ចនៃភាគីពាក់ព័ន្ធ ឬ/និងទំនាស់តិចតួចទាក់ទិនការចុះឈ្មោះបោះឆ្នោត ការអប់រំផ្សព្វផ្សាយអំពីការចុះឈ្មោះបោះឆ្នោត ការសង្កេតការណ៍ ។ល។ យន្តការនេះមានសមាសភាពពីសមាជិក គ.ជ.ប មន្ត្រី គ.ជ.ប មន្ត្រីនៃគណៈអចិន្ត្រៃយ៍សន្តិសុខបោះឆ្នោត មន្ត្រីនៃគណបក្សចុះឈ្មោះប្រកួតប្រជែងក្នុងការបោះឆ្នោត និងតំណាងអង្គការសមាគម មិនមែនរដ្ឋាភិបាល សង្កេតការណ៍បោះឆ្នោត។ យន្តការរួមនេះ គួរតែត្រូវបង្កើតនៅកំរិតថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រោមការដឹកនាំរបស់សមាជិក គ.ជ.ប។

## ខ.៣ វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដើម្បីលើកស្ទួយ និងការពារសិទ្ធិអ្នកចំណាកស្រុក និងធ្វើការនៅក្រៅប្រទេស

យោងតាមមាត្រា ១៥០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គ.ជ.ប ធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងមាត្រា ៤២ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវ ដោយចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងមាត្រា ៤៣ នៃច្បាប់នេះ គ.ជ.ប ធ្វើ និងជូនរបាយការណ៍ទៅរដ្ឋសភា។ ដូចនេះរបាយការណ៍របស់ គ.ជ.ប គួរបញ្ចូលអំពីបញ្ហានៃការចុះឈ្មោះបោះឆ្នោតមិនទាន់ពេញលេញចំពោះពលករ ឬប្រជាពលរដ្ឋចំណាកស្រុក និងមន្ត្រីស្ថានទូតធ្វើការនៅបរទេស។

អ្នកតំណាងរាស្ត្រ ពិនិត្យរបាយការណ៍របស់ គ.ជ.ប ហើយអញ្ជើញ គ.ជ.ប ក្រសួងមហាផ្ទៃ និងអ្នកជំនាញបោះឆ្នោត ដើម្បីពន្យល់អំពីបញ្ហា និងរកដំណោះស្រាយ។ តំណាងរាស្ត្រគួរធ្វើសេចក្តីស្នើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីផ្តល់សិទ្ធិអំណាច និងបង្កើតនីតិវិធីឱ្យ គ.ជ.ប ធ្វើការចុះឈ្មោះបោះឆ្នោតដល់ពលករចំណាកស្រុក និងមន្ត្រីស្ថានទូតធ្វើការនៅបរទេស យ៉ាងហោចណាស់មានអន្តរប្បញ្ញត្តិពិសេស ឱ្យសាកល្បងនៅត្រឹមប្រទេសថៃសិន។ វិសោធនកម្មច្បាប់នេះ ដើម្បីបង្កើតឱ្យមានការិយាល័យចុះឈ្មោះបោះឆ្នោត នៅស្ថានទូតស្ថានកុងស៊ុល និងទីតាំងក្បែររោងចក្រ ឬកន្លែងធ្វើការរបស់ពលករខ្មែរក្នុងប្រទេសថៃ ឬនៅការិយាល័យច្រកចេញចូលតែមួយ (នៅប្រទេសថៃ មានច្រកចេញចូលចំនួន ១០កន្លែងក្នុងចំណោម ៨០កន្លែងដែលមានមន្ត្រីខ្មែរបានធ្វើការនៅទីនោះ) និងប្រើប្រាស់ពេលវេលានៅថ្ងៃសៅរ៍ ឬអាទិត្យ ដោយសុំសហការជាមួយអាជ្ញាធរថៃ។